# ធនាគារ ព្រីនស៍ ម.ក

## បញ្ញត្តិ និងលក្ខខណ្ឌសម្រាប់កម្មវិធីលើកទឹកចិត្តប្រើប្រាស់ប័ណ្ណ VISA ជាមួយកាល់តិច

ធនាគារ ព្រីនស៍ ម.ក ("**ធនាគារ ព្រីនស៍**") កំពុងដាក់ដំណើរការកម្មវិធីលើកទឹកចិត្តប្រើប្រាស់ប័ណ្ណ VISA ជាមួយកាល់តិច ដោយអនុលោមតាមបញ្ញត្តិ និងលក្ខខណ្ឌ ដែលបានចែងនៅទីនេះ ("**កម្មវិធីលើកទឹកចិត្ត**")។ តាមរយៈការចូលរួមកម្មវិធីលើកទឹកចិត្តនេះ អតិថិជន យល់ព្រមអនុវត្តតាមបញ្ញត្តិ និងលក្ខខណ្ឌដូចខាងក្រោម ព្រមទាំងបញ្ញត្តិ និងលក្ខខណ្ឌទូទៅ បញ្ញត្តិ និងលក្ខខណ្ឌនៃការប្រើប្រាស់ប័ណ្ណឥណទាន បញ្ញត្តិ និងលក្ខខណ្ឌនៃការប្រើប្រាស់ប័ណ្ណ និងបញ្ញត្តិ និងលក្ខខណ្ឌដែលពាក់ព័ន្ធដទៃទៀត៖

១. រាល់អតិថិជនចាស់ និងអតិថិជនថ្មីជារូបវន្តបុគ្គលដែលកំពុងប្រើប្រាស់ប័ណ្ណឥណពន្ធ ឬប័ណ្ណឥណទាន VISA (ប្រភេទ Classic ឬ Platinum) ចេញជូនដោយ ធនាគារ ព្រីនស៍ ("**អ្នកចូលរួម**") អាចចូលរួមកម្មវិធីលើកទឹកចិត្តនេះ។

២. អតិថិជនដែលបានបំពេញលក្ខខណ្ឌដូចខាងក្រោម នឹងទទួលបាននូវរង្វាន់លើកទឹកចិត្ត ("**រង្វាន់លើកទឹកចិត្ត**") ស្របតាមបញ្ញត្តិ និងលក្ខខណ្ឌខាងក្រោម។

| **ប្រភេទប្រតិបត្តិការ** | **ពាណិជ្ជករ** | **រង្វាន់លើកទឹកចិត្ត (សាច់ប្រាក់ត្រឡប់វិញ)** | | **រយៈពេលកម្មវិធីលើកទឹកចិត្ត** |
|---|---|---|---|---|
| | | **ប្រភេទ Classic** | **ប្រភេទ Platinum** | |
| រាល់ប្រតិបត្តិការទិញ តាមម៉ាស៊ីនឆូតកាត ដោយប្រើប្រាស់ប័ណ្ណ VISA ធនាគារ ព្រីនស៍ (ទាំងប័ណ្ណឥណពន្ធ ឬប័ណ្ណឥណទាន) | ស្ថានីយ៍ប្រេងឥន្ធនៈកាល់តិច (ក្រុមហ៊ុន ឈេហ្វរ៉ុន (ខេមបូឌា) លីមីធីត) ដូចមានភ្ជាប់នៅឧបសម្ព័ន្ធ១ | ១៥% នៃវិក្កយបត្រ (កម្រិតត្រឹម ២៥$ ក្នុងមួយខែ) | ២៥% នៃវិក្កយបត្រ (កម្រិតត្រឹម ៣៥$ ក្នុងមួយខែ) | ១០ មេសា ដល់ ១០ កក្កដា ២០២៤ |

(*សម្គាល់៖ រង្វាន់លើកទឹកចិត្តនឹងផ្តល់ជូនយ៉ាងយូរត្រឹមថ្ងៃទី២៥ នៃខែបន្ទាប់នៃប្រតិបត្តិការ)

៣. ដោយមិនមានតម្រូវឱ្យមានការទាមទារណាមួយពីអ្នកចូលរួម រង្វាន់លើកទឹកចិត្តក្នុងទម្រង់ជាការប្រគល់សាច់ប្រាក់ត្រឡប់វិញ នឹងត្រូវបានដាក់ចូលទៅក្នុងគណនីចរន្ត ឬគណនីសន្សំដែលភ្ជាប់ជាមួយនឹងប័ណ្ណឥណទាន ឬប័ណ្ណឥណពន្ធរបស់អ្នកចូលរួម ដែលត្រូវបានប្រើប្រាស់ដើម្បីធ្វើប្រតិបត្តិការបញ្ជាទិញ ដោយអនុលោមតាមបញ្ញត្តិ និងលក្ខខណ្ឌនេះ ដោយស្វ័យប្រវត្តិ។ សាច់ប្រាក់ដែលនឹងត្រូវទទួលត្រឡប់វិញ នឹងត្រូវបានផ្តល់ជូនអ្នកចូលរួម ដោយអនុលោមតាម បញ្ញត្តិ និងលក្ខខណ្ឌនេះ នៅក្នុងរយៈពេលកម្មវិធីលើកទឹកចិត្ត ឬរហូតដល់ពេលដែលគម្រោងថវិការដែលត្រូវបានអនុម័តសម្រាប់កម្មវិធីលើកទឹកចិត្តនេះ ត្រូវបានចំណាយអស់។

៤. ប្រសិនបើគណនីចរន្ត ឬគណនីសន្សំដែលភ្ជាប់ជាមួយនឹងប័ណ្ណឥណទាន ឬប័ណ្ណឥណពន្ធ ត្រូវបានបិទមុនកាលបរិច្ឆេទនៃការប្រគល់សាច់ប្រាក់ត្រឡប់វិញ ដូចបានចែងនៅក្នុងបញ្ញត្តិនិងលក្ខខណ្ឌនេះ ហើយម្ចាស់ប័ណ្ណបានបញ្ចប់ទំនាក់ទំនងជាមួយ ធនាគារ ព្រីនស៍ (មិនបន្តប្រើប្រាស់ប័ណ្ណឥណទាន ឬ

ប័ណ្ណឥណពន្ធ ប្រភេទណាមួយរបស់ VISA ដែលចេញដោយ ធនាគារ ព្រីនស៍) នោះម្ចាស់ប័ណ្ណនឹងមិនមានសិទ្ធិក្នុងការទទួលបាន ឬទាមទារយករង្វាន់លើកទឹកចិត្តដែលបានផ្តល់ជូន នៅក្រោមកម្មវិធីលើកទឹកចិត្តនេះឡើយ។

៥. ក្នុងករណីមានការឆបោក ឬក្លែងបន្លំដែលប្រព្រឹត្តដោយ ឬមានពាក់ព័ន្ធនឹងអ្នកចូលរួមទាក់ទងនឹងកម្មវិធីលើកទឹកចិត្តនេះ អ្នកចូលរួមរូបនោះនឹងបាត់បង់សិទ្ធិចូលរួមកម្មវិធីលើកទឹកចិត្តនេះ ដោយរួមទាំងអត្ថប្រយោជន៍ផ្សេងៗដែលខ្លួនទទួលបាន។ អ្នកចូលរួមត្រូវប្រគល់ជូនធនាគារ ព្រីនស៍ វិញ នូវរាល់អត្ថប្រយោជន៍ដែលខ្លួនបានទទួលពី ធនាគារ ព្រីនស៍ តាមរយៈកម្មវិធីលើកទឹកចិត្តនេះ (ប្រសិនបើមាន) និងត្រូវសងសំណងការខូចខាតផ្សេងៗទៅតាមបញ្ញត្តិច្បាប់ជាធរមាន។

៦. ការរក្សាសិទ្ធិ ការរួចផុត និងការកម្រិតនៃការទទួលខុសត្រូវ

ក. អ្នកចូលរួម យល់ព្រមថា ធនាគារ ព្រីនស៍ រួមបញ្ចូលទាំង ម្ចាស់ភាគហ៊ុន អភិបាល ឬបុគ្គលិករបស់ ធនាគារ ព្រីនស៍ មិនត្រូវទទួលខុសត្រូវលើ រាល់ការខូចខាតណាមួយ ទោះដោយផ្ទាល់ ឬដោយប្រយោល ជាពិសេស ឬដោយចៃដន្យ ដែលកើតឡើង ទាក់ទងនឹងកម្មវិធីលើកទឹកចិត្តនេះឡើយ។

ខ. អ្នកចូលរួម យល់ព្រមដោយមិនអាចដកហូតវិញបានថា អ្នកចូលរួមយល់ព្រមសងសំណង និងធានាថា ធនាគារ ព្រីនស៍ នឹងទទួលបានសំណងគ្រប់ពេលណាមួយ លើរាល់ការបាត់បង់ ការខូចខាត កម្រៃសេវា កម្រៃសេវាផ្លូវច្បាប់ និងការចំណាយផ្សេងៗ និងរាល់ផលវិបាកដែលកើតឡើងលើធនាគារ ព្រីនស៍ ឬបានទទួលរងដោយ ធនាគារ ព្រីនស៍ ចំពោះការទាមទារ ឬបណ្តឹងណាមួយដែលធ្វើឡើងដោយអ្នកចូលរួម ឬភាគីទីបី ដែលកើតឡើង ឬទាក់ទងនឹងបញ្ញត្តិដែលមានចែងក្នុងបញ្ញត្តិនិងលក្ខខណ្ឌនេះ។

គ. ធនាគារ ព្រីនស៍ មិនទទួលខុសត្រូវ ទោះក្នុងទម្រង់ណាមួយ ចំពោះការខូចខាត ឬការខាតបង់ដែលកើតចេញពីប្រតិបត្តិការរវាងអ្នកចូលរួម និងស្ថានីយ៍ប្រេងឥន្ធនៈកាល់តិចឡើយ។

៧. ធនាគារ ព្រីនស៍ រក្សាសិទ្ធិគ្រប់យ៉ាង ក្នុងការធ្វើវិសោធនកម្មលើបញ្ញត្តិនិងលក្ខខណ្ឌនេះ ពន្យាពេលបន្ថែមរយៈពេល ឬលុបចោលកម្មវិធីលើកចិត្តនេះ និង/ឬរង្វាន់លើកទឹកចិត្ត នៅពេលណាមួយក្នុងរយៈពេលកម្មវិធីលើកទឹកចិត្ត ដោយមិនមានការទទួលខុសត្រូវ តាមឆន្ទានុសិទ្ធិដាច់ខាតរបស់ ធនាគារ ព្រីនស៍ ដោយគ្រាន់តែផ្តល់ការជូនដំណឹងពីការផ្លាស់ប្តូរ នៅលើគេហទំព័រផ្លូវការ ឬតាមមធ្យោបាយទំនាក់ទំនងផ្សេងទៀតរបស់ ធនាគារ ព្រីនស៍។

៨. បញ្ញត្តិនិងលក្ខខណ្ឌនេះ ត្រូវបានគ្រប់គ្រងដោយច្បាប់ជាធរមាននៃព្រះរាជាណាចក្រកម្ពុជា។ រាល់វិវាទដែលកើតឡើង ឬទាក់ទងនឹងកម្មវិធីលើកទឹកចិត្តនេះ នឹងត្រូវបានដោះស្រាយ ដោយអនុលោមតាមគោលនយោបាយដោះស្រាយបណ្តឹងអតិថិជនរបស់ធនាគារ និងតុលាការមានសមត្ថកិច្ចនៃព្រះរាជាណាចក្រកម្ពុជា។

## ឧបសម្ព័ន្ធ១

## បញ្ជីស្ថានីយ៍ប្រេងឥន្ធនៈកាល់តិចទាំង៧០ ដែលចូលរួម

| ល.រ | ឈ្មោះស្ថានីយ៍ | រាជធានី/ខេត្ត |
|---|---|---|
| ១ | CALTEX KAMPONG CHAM | កំពង់ចាម |
| ២ | CALTEX POCHENTONG | ភ្នំពេញ |
| ៣ | CALTEX ROAD 6A | ភ្នំពេញ |
| ៤ | CALTEX APSARA | ភ្នំពេញ |
| ៥ | CALTEX BOKOR | ភ្នំពេញ |
| ៦ | CALTEX ROAD 5B | ភ្នំពេញ |
| ៧ | CALTEX CALMETTE | ភ្នំពេញ |
| ៨ | CALTEX MEKONG | ភ្នំពេញ |
| ៩ | CALTEX TOEUK LAORK | ភ្នំពេញ |
| ១០ | CALTEX CHAK ANGRE | ភ្នំពេញ |
| ១១ | CALTEX CHBAR AMPEAUV | ភ្នំពេញ |
| ១២ | CALTEX BOEUNG TRABEK | ភ្នំពេញ |
| ១៣ | CALTEX PETLOKSANG | ភ្នំពេញ |
| ១៤ | CALTEX BEUNG KENG KANG | ភ្នំពេញ |
| ១៥ | CALTEX PSAR DEUMKOR | ភ្នំពេញ |
| ១៦ | CALTEX SIHANOUKVILLE - 2 | ព្រះសីហនុ |
| ១៧ | CALTEX ANGKOR | សៀមរាប |
| ១៨ | CALTEX PSAR DEIHOY | ភ្នំពេញ |
| ១៩ | CALTEX STOEUNG MEANCHEY | ភ្នំពេញ |
| ២០ | CALTEX SIHANOUKVILLE - 1 (KLANG LEU) | ព្រះសីហនុ |
| ២១ | CALTEX SEN SOK | ភ្នំពេញ |
| ២២ | CALTEX LOKTA DOMBANG KRONHONG | បាត់ដំបង |
| ២៣ | CALTEX PREK TAMAK STATION | កណ្តាល |

| | | |
|---|---|---|
| ២៤ | CALTEX ANG TASOM STATION | តាកែវ |
| ២៥ | CALTEX BAYONG MEANCHEY | ភ្នំពេញ |
| ២៦ | CALTEX ROAD 2004 STATION | ភ្នំពេញ |
| ២៧ | CALTEX AEON 2 STATION | ភ្នំពេញ |
| ២៨ | CALTEX KAMPOT STATION | កំពត |
| ២៩ | CALTEX PHSAR DAEUM THKOV 271 PETROL | ភ្នំពេញ |
| ៣០ | CALTEX TAKHMAO | កណ្ដាល |
| ៣១ | CALTEX SKUN | កំពង់ចាម |
| ៣២ | CALTEX TAKEO | តាកែវ |
| ៣៣ | CALTEX STREET 1986 | ភ្នំពេញ |
| ៣៤ | CALTEX SIEM REAP (CHONG KAO SOU) | សៀមរាប |
| ៣៥ | Caltex Toul Pungror | ភ្នំពេញ |
| ៣៦ | CALTEX KRAING THNUNG | ភ្នំពេញ |
| ៣៧ | Caltex Odem station | ភ្នំពេញ |
| ៣៨ | Caltex TK Street 592 | ភ្នំពេញ |
| ៣៩ | Caltex Suong | ត្បូងឃ្មុំ |
| ៤០ | Caltex Chamkar Dong | ភ្នំពេញ |
| ៤១ | CALTEX BATTAMBANG THMEY | បាត់ដំបង |
| ៤២ | Caltex Angsnoul | កណ្ដាល |
| ៤៣ | Caltex Poi Pet | បន្ទាយមានជ័យ |
| ៤៤ | Caltex Kampong Thom | កំពង់ធំ |
| ៤៥ | Caltex KRONG BAVET 2 | ស្វាយរៀង |
| ៤៦ | Caltex Beung kok | ភ្នំពេញ |
| ៤៧ | Caltex Banteay Mean Chey | បន្ទាយមានជ័យ |

| | | |
|---|---|---|
| ៤៨ | Caltex Kampong Speu | កំពង់ស្ពឺ |
| ៤៩ | Caltex Chhouk Meas<br>RORO | ភ្នំពេញ |
| ៥០ | Caltex Prey Sar Road<br>RORO | ភ្នំពេញ |
| ៥១ | Caltex Mittapheap<br>RORO | ព្រះសីហនុ |
| ៥២ | Caltex Tang Korsang<br>RORO | ភ្នំពេញ |
| ៥៣ | Caltex Mundol Kiri<br>RORO | មណ្ឌលគិរី |
| ៥៤ | Caltex Road No 3<br>RORO | ភ្នំពេញ |
| ៥៥ | Caltex Road 598<br>RORO | ភ្នំពេញ |
| ៥៦ | Caltex Angkor Blvd<br>RORO | ភ្នំពេញ |
| ៥៧ | Caltex Korkie Market<br>RORO | កណ្ដាល |
| ៥៨ | Caltex Takhmao Road 21<br>RORO | កណ្ដាល |
| ៥៩ | Caltex Plaza<br>RORO | ភ្នំពេញ |
| ៦០ | Caltex La Ang<br>RORO | កំពត |
| ៦១ | Caltex Pich Nil<br>RORO | កំពង់ស្ពឺ |
| ៦២ | Caltex KM33 (Kandal Stueng) | កណ្ដាល |
| ៦៣ | Caltex Toul Kork Pen Nuth<br>RORO | ភ្នំពេញ |
| ៦៤ | Caltex 7 Makara<br>RORO | សៀមរាប |
| ៦៥ | Caltex Pouk Market<br>RORO | សៀមរាប |
| ៦៦ | Caltex Prek Pnov | ភ្នំពេញ |

| | | |
|---|---|---|
| | RORO | |
| ៦៧ | Caltex Tiger Beer Road - Prek Eng<br>RORO | ភ្នំពេញ |
| ៦៨ | Caltex Kob Srov Road<br>RORO | ភ្នំពេញ |
| ៦៩ | Caltex Krek<br>RORO | កំពង់ចាម |
| ៧០ | Caltex Tonle Om<br>RORO | កំពង់ចាម |